ការសម្ភាសរបស់លោកយាយ ពុំ រិន

ក៖ អ្នកដែរសម្ភាសឈ្មោះថា ជាង ស៊ីអ៊ាវ

ខ៖ អ្នកទទួលការសម្ភាសឈ្មោះថា ពុំ រិន៖

<u>ការសង្ខេបប្រវត្តិរបស់លោកយាយ ពុំ រិន</u>

លោកយាយ ពុំ រិន មានអាយុ ៧០ឆ្នាំ នៅក្នុងឆ្នាំ២០១៩ ភេទស្រី មានទីលំនៅបច្ចុប្បន្ននៅភូមិខ្សាច់លុប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ៖

ក៖ ចឹងជាដំបូងខ្ញុំអរគុណច្រើនយាយដែរបានអោយចៅពិភាក្សាជាមួយយាយទាក់ទងពីប្រវត្តិរបស់យាយ

ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិច ដែរមានឈ្មោះថា..?

ខ៖ ចា៎!

ក៖ អើBYUហើយដោយសារតែសកលវិទ្យាល័យ មានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ

ដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិឪពុកម្តាយហ្នឹងអ្នកតា

ចឹងសំរាប់យាយយល់ព្រមដើម្បីអោយចៅដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយសាណាលទេយាយ?

ខ៖ ចា៎!

ក៖ បាទចឹងសំរាប់ចៅជាអ្នកសម្ភាសយាយចៅមានឈ្មោះថាជាង

ស៊ីអ៊ាវហើយថ្ងៃខែចៅសម្ភាសយាយគឺនៅថ្ងៃទី៨ខែ២ឆ្នាំ២០១៩ហើយការសម្ភាសទាំងអស់នេះគឺធ្វើឡើងនៅភូមិអើភូមិភូមិហ្នឹងភូមិអីគេយាយ?

ខ៖ នេះភូមិខ្សាច់លុប។

ក៖ ភូមិខ្សាច់លុប?ដដេត

ខ៖ អើឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។រតយេរ

ក៖ អ៊ុំបាទយាយចុះសំរាប់យាយឈ្មោះពេញទាំងត្រកូលរបស់យាយឈ្មោះអីគេយាយ?

ខ៖ ខ្ញុំឈ្មោះអើពុំ រិន។

ក៖ អ៊ុំចុះមានឈ្មោះហៅក្រៅអត់យាយ?

ខ៖ ហ្នឹងហៅតែចឹងម៉ងអត់មានឈ្មោះពីរបីទេកូន។

ក៖ ពុំរិនចឹងម៉ងណេះយាយ?

ខ៖ ចាំតែពុំរិនចឹងម៉ង។

ក៖ អ៊ុំចុះអើចឹងយាយសព្វថ្ងៃយាយអាយុប៉ុន្មានទៅយាយ?

ខ៖ ខ្ញុំវាចូលចិតហើយឆ្នាំហ្នឹង!

ក៖ អ៊ុំចូលចិតណេះយាយ?

ខ៖ ចាំឆ្នាំថោះ។

ក៖ អ៊ុំចុះយាយគិតថាអើយាយកើតនៅឆ្នាំណាយាយចាំអត់យាយ?

ខ៖ ខ្ញុំឆ្នាំហាគត់ហោស។

ក៖ មួយពាន់ប្រាំបួនរយហាគត់ហោសយាយ?

ខ៖ មួយពាន់ប្រាំបួនរយហាគត់ចា៎!

ក៖ បាទយាយចុះយាយសំរាប់ឆ្នាំច័ន្ទគតិជូត ឆ្លូ ខាល ថោះយាយឆ្នាំអីគេយាយ?

ខ៖ ចា៎?

ក៖ ឆ្នាំជូត ឆ្លូ ខាល ថោះយាយឆ្នាំអីគេទៅ?

ខ៖ ខ្ញុំឆ្នាំថោះ។

ក៖ អ៊ុំបាទយាយចុះសំរាប់យាយគិតថាអើយាយកើតស្រុកកំណើតរបស់យាយកើតយាយកើតនៅណាយាយ?

ខ៖ ខ្ញុំកើតនៅភូមិស្ទុកព្រៃ។

ក៖ នៅឃុំអីយាយ?

ខ៖ នៅឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។

ក៖ ចឹងនៅជិតហ្នឹងទេ?

ខ៖ ចាំនៅហ្នឹង!

ក៖ អ៊ុំ!

ខ៖ ខាងលិចឃុំខ្សាច់លុបនេះ។

ក៖ បាទយាយបាទ!

ខ៖ ចា៎!

ក៖ ចុះយាយគិតថាសំរាប់អ្ងចជាយាយមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់យាយ?

ខ៖ ខ្ញុំបងប្អូនបង្កើតមានប្រាំនាក់ប៉ុនស្ពាប់មួយហើយនៅបួន។

ក៖ អ៉ូបាទយាយ!

ខ៖ ចាំ!

ក៖ ចុះយាយជាកូនទីប៉ុន្មានទៅយាយ?

ខ៖ ខ្ញុំកូនទីបី។

ក៖ អ៉ូ!

ខ៖ អ៉ូទីពីរ។

ក៖ ប៉ុន្តែអ្នកដែរស្ពាប់ហ្នឹងកូនទីប៉ុន្មានយាយ?

ខ៖ កូនទីប្រាំកូនទីបួន។

ក៖ អ៉ូគាត់ស្ពាប់ដោយសារអីគេយាយ?

ខ៖ រាណ៏!

ក៖ អ៉ូចឹងហោសយាយ?

ខ៖ កូនស្រីប្អូនស្រី។

ក៖ បាទយាយបាទចុះយាយគិតថាអើយាយអាចប្រាប់ឈ្មោះបងប្អូនយាយបានទេថាពួកគាត់មានឈ្មោះអីគេខ្លះចឹងហាសយាយ?

ខ៖ ប្អូនបងខ្ញុំទីមួយគាត់ឈ្មោះអើពុំ រស់។

ក៖ ចុះទីពីរយាយ?

ខ៖ ទីពីរអើពុំ លិប។

ក៖ ចុះទីបី?

ខ៖ ទីបីឌីពុកផ្សេងគ្នា។

ក៖ អ៉ូចឹង!

ខ៖ គាត់ឈ្មោះអើទីបីគាត់ឈ្មោះអើម៉ៃ លូត។

ក៖ អ៉ូ!

ខ៖ ហើយមួយទៀតឈ្មោះម៉ៃអើ ម៉ៃ នាង។

ក៖ អ៉ូដល់ពេលពៅគេ?

ខ៖ ចាំពៅគេប្រុស។

ក៖ ម៉ៃនាងហ្នឹងហោសយាយ?

ខ៖ ចាំ!

ក៖ ប៉ុន្តែបងប្អូនរបស់យាយមានគ្រួសារអស់ហើយណោះយាយណោះ?

ខ៖ បងប្អូនបែកអស់ហើយ!

ក៖ អ៉ូ!

ខ៖ ចាំ!

ក៖ ប៉ុន្តែអូចជាយាយធ្លាប់ធ្វើអីគេខ្លះជាមួយបងប្អូនយាយកាលនៅក្មេងអត់យាយ?

ខ៖ យើងធ្វើស្រែធម្មតាកូនប៉ុនខ្ញុំកំព្រាតាំងពីកំពស់នេះហោសកំព្រាឌីពុក។

ក៖ អ៉ូបាទយាយបាទ!

ខ៖ ចាំឌីពុកមុនហ្នឹងហាស!

ក៖ បាទយាយ!

ខ៖ ចាំដល់មកបានអាយុប្រហែលជាថាដប់ឆ្នាំហើយកំព្រាម្តាយទៀត។

ក៖ បាទយាយ!

ខ៖ ចាំដែងម៉ៃគាត់យកគ្រួសារក្រោយទៀតទៅគាត់ឈឺគាត់ស្ពាប់ទៅ។

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាអើចឹងបងប្អូនរបស់យាយសព្វថ្ងៃគាត់នៅខេត្តណាខ្លះទៅយាយ?

ខ៖ នៅមូលគ្នាហ្នឹងទាំងអស់។

ក៖ នៅហ្នឹង?

ខ៖ ពីរនាក់នៅខ្សាច់លុប នៅពុំ រស់មួយនៅខ្សាច់លុប ពុំ រិននៅខ្សាច់លុបអើពុំ លិបនៅខ្សាច់លុប។

ក៖ បាទយាយ!

ខ៖ ហើយខ្ញុំនៅអើស្តុបព្រៃ ពុំរិន នៅស្តុបព្រៃហើយអើនេះម៉ាក់អាម៉ៃអើចឹងហើយអើនាងហ្នឹងហ្នឹងនៅស្តុបព្រៃដែរនៅជិតគ្នាហ្នឹង!

ក៖ អ៊ូ!

ខ៖ អត់មានទៅណាឆ្ងាយទេកូនៅហ្នឹងតែជាមួយគ្នា។

ក៖ បាទយាយបាទ!

ខ៖ នៅហ្នឹងទាំងអស់។

ក៖ អ៊ូបាទយាយ!

ខ៖ ដល់យើងធ្វើស្រែធម្មតាហ្នឹងហាសកូន។

ក៖ បាទយាយបាទចុះយាយគិតថាដូចជាចឹងដូចជាឪពុករបស់យាយឈ្មោះអីគេយាយ?

ខ៖ ឈ្មោះពុំ។

ក៖ ចុះម្តាយរបស់យាយ?

ខ៖ ឈ្មោះ សុំ។

ក៖ អ៊ូចុះឥឡូវពួកគាត់ស្លាប់អស់ហើយ?

ខ៖ អើស្លាប់តាំងពីខ្ញុំនៅកំពស់នេះណោះឪពុក។

ក៖ បាទ!

ខ៖ ហើយម្តាយខ្ញុំបានដប់ឆ្នាំម្តាយស្លាប់ទៀតទៅ។

ក៖ បាទយាយបាទ!

ខ៖ ហ្នឹងឯងខ្ញុំរស់នៅជាមួយជីដូន។

ក៖ អ៊ូបាទ!

ខ៖ ជីដូនហ្នឹងមែនជីដូនបង្កើតទេជីដូនមីងដែរប្អូនយាយខ្ញុំហាស!

ក៖ បាទយាយ!

ខ៖ ម៉ែខ្ញុំក៏គាត់កំព្រាតាំងគាត់អាយុដប់ពីរហាស!

ក៖ បាទយាយ!

ខ៖ ចា៎!

ក៖ ចុះយាយគិតថាអើឪពុកម្តាយយាយគាត់អ្នកស្រុកនៅណាយាយ?

ខ៖ នៅហ្នឹងទាំងអស់ហ្នឹងម៉ង។

ក៖ នៅហ្នឹងណេះយាយណេះ?

ខ៖ ចា៎កំណើតកើតជាយើងនៅហ្នឹង!

ក៖ បាទយាយ!

ខ៖ ចា៎!

ក៖ ចុះយាយគិតថាកាលឪពុករបស់យាយគាត់នៅរស់គាត់នៅក្មេងហាសគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅយាយ?

ខ៖ គាត់ឡើងភ្នោត។

ក៖ គាត់ឡើងតែភ្នោតទេណេះយាយ?

ខ៖ ចា៎ឡើងតែភ្នោតធ្វើតែស្រែយើងធម្មតា។

ក៖ ក្រូវស្ករភ្នោតដែរទៅ?

ខ៖ ចា៎គាត់ឡើងភ្នោតរំងាស់ហាសកូន។

ក៖ អ៊ូ!

ខ៖ ចា៎!

ក៖ ចុះគាត់អត់មានទៅធ្វើការអីផ្សេងទេណេះយាយណេះ?

ខ៖ អត់ទេអត់ទេ។

ក៖ អ៊ូបាទយាយចុះយាយគិតថាអើម្តាយរបស់យាយគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅយាយ?

ខ៖ គាត់ធ្វើស្រែ។

ក៖ ធ្វើតែស្រែទេណេះយាយ?

ខ៖ ចា៎ធ្វើតែស្រែហើយឪហ្នឹងពុកហ្នឹងគាត់នេះទៅគាត់អើនេះគាត់ធ្វើភ្នោតធ្វើអីចឹងទៅ។

ក៖ បាទយាយ!

ខ៖ ចា៎យងស្រុកនេះយើងពីដើមកូនយើងធ្វើអីគេសូម្បីតែយាយតាយើងក៏ធ្វើភ្នោត។

ក៖ បាទយាយត្រូវ។

ខ៖ ចា៎!

ក៖ អ៊ូចុះយាយគិតថាអើឪពុកម្តាយយាយគាត់កាចរឹក៏ស្ងួតយាយ?

ខ៖ អ្ងំឪពុកខ្ញុំស្លូតណាស់ចាស់ៗគាត់និយាយគាត់ថាស្លូតណាស់។

ក៖ អ្ងំបាទយាយ!

ខ៖ ចាំម៉ែខ្ញុំក៏ស្លូតដែរ។

ក៖ អ្ងំ!

ខ៖ អត់ចេះទៅទំនាស់ឈ្លោះកាចជាមួយបងប្អូនញាតិមិត្តណាទេគាត់ស្រឡាញ់បងប្អូនគាត់ណាស់។

ក៖ បាទយាយ!

ខ៖ ប៉ុនធ្វើម៉េចកម្មអកុសលរបស់យើងហាស!

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖

ចុះយាយគិតយាយធ្លាប់មានអនុស្សាវរីយ៍អីជាមួយឪពុកម្តាយយាយកាលយាយនៅជាមួយពួកគាត់ទេធ្លាប់ដូចជាធ្លាប់ទៅប្រែរឹមួយក៏ធ្វើអីជាមួយឪពុកម្តាយយាយដែរយាយចាំអត់ហ្ហ

ចហាស?

ខ៖ យើងនៅតូចៗកូន។

ក៖ អ្ងំ!

ខ៖ ចាំយើងនៅតូចៗ។

ក៖ បាទយាយ!

ខ៖ ហើយដល់ខ្ញុំចេះមើលប្អូនហ្នឹងអាយុប្រាំពីរប្រាំបីឆ្នាំហ្នឹងម៉ែហ្នឹងគាត់ផ្ទាយទៅនៅជាមួយឪពុកមាអ៊ីទន្លេហោស!

ក៖ បាទយាយ!

ខ៖ ចាំតែម្តាយស្លាប់ហ្នឹងក៏យើងអត់ទាន់ដង្ហើមដែរយើងអត់ឃើញមុខដែរ។

ក៖ បាទយាយ!

ខ៖ ផើយយើងនៅស្រុកទន្លេអីគេហៅស្ទឹងកូនប្ដែហាសណាស់កូនឯងស្ទឹងលង់សេកហាសកូន។

ក៖ បាទយាយ!

ខ៖ ចាំទន្លេហោស!

ក៖ អ្ងំ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាឪពុករបស់យាយគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅយាយទេ?

ខ៖ ចុះបើខ្ញុំនៅកំពស់នេះខ្ញុំអត់ដឹងអីផងប្អូនខ្ញុំពុំ លិបហ្នឹងនៅក្នុងពោះប្រាំពីរខែហ្នឹង!

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ ចុះម្តាយយាយវិញគាត់ធ្លាប់ប្រាប់ទេ?

ខ៖ គាត់អត់ដែរមាននិយាយអីទេហើយម៉ែខ្ញុំស្លូតសឹងអីខ្ញុំនៅតូចៗដល់ផើឪពុកមាហ្នឹង

ម្តាយមីងសាច់ផ្ទៃហ្នឹងគេអត់ណាជួយមើលកូនគេមកសុំក៏ផ្ទាយទៅគេសុំយកទៅមើលជួយមើលប្អូនប្អូនជីដូនមួយហ្នឹងគាត់ផ្ទាយទៅហើយយើងមានដែរបានៅជាមួយគាត់ណា។

ក៖ អ្ងំ!

ខ៖ ចាំ!

ក៖ បាទយាយចុះម្តាយរបស់យាយវិញគាត់ធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅយាយទេ?

ខ៖ ម៉ែខ្ញុំហោស?

ក៖ បាទ!

ខ៖ គាត់គាត់អត់ដែរនិយាយអីផង។

ក៖ អ្ងំបាទយាយចុះជីដូនជីតាខាងឪពុកយាយស្គាល់ឈ្មោះគាត់ទេ?

ខ៖ ផើជីដូនជីតាផើខាងម៉ែខ្ញុំឈ្មោះផើតាជិ: តាទូច។

ក៖ ចុះជីដូនជីតាខាងឪពុក?

ខ៖ ផើឈ្មោះផើតាពុកយាយកិន។

ក៖ អ្ងំ!

ខ៖ ប៉ុនដែរខ្ញុំអត់ស្គាល់ទេកូនគាត់នេះអស់ហើយគាត់សុទ្ធតែស្លាប់អស់ហើយខ្ញុំអត់ស្គាល់គាត់ទេគ្រាន់ដែរស្គាល់តែឈ្មោះហាសកូន។

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាយាយមករស់នៅហ្នឹងអស់រយៈពេលប៉ុន្មានឆ្នាំហើយយាយ?

ខ៖ ម៉ែខ្ញុំមកពីឆ្នាំប៉ុន្មានមើលវាស្លាប់ឆ្នាំឆ្លូវដប់ឆ្នាំហើយហី!

ក៖ អ្ចឹងជាងដប់ឆ្នាំហើយណោះ?

ខ៖ ដប់ហើយប៉ុន្តែខ្ញុំវាដាក់ទៅវិញពីរឆ្នាំមើលចៅកំព្រាឱពុកបានមួយខួប។

ក៖ អ្ចឹ!

ខ៖ បួនខែម្តាយវាស្លាប់ហាសកូន។

ក៖ បាទយាយ!

ខ៖ កូនប្រសារហ្នឹងហាស!

ក៖ បាទៗចុះ..?

ខ៖ ហើយកូនយើងប្រុស។

ក៖ បាទយាយចុះយាយគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសារយាយទៅធ្លាប់ទៅនៅក្រៅអត់យាយក្រៅប្រទេសហាស?

ខ៖ អត់ទេអត់ទេ។

ក៖ អត់មានទេណោះយាយអ្ចឹចុះអើស្វាមីរបស់យាយឈ្មោះអីគេយាយ?

ខ៖ ស្វាមីងខ្ញុំហេស?

ក៖ បាទ!

ខ៖ ឈ្មោះអើសុំ ឯម។

ក៖ ប៉ុន្តែគាត់ឥឡូវគាត់ធ្វើអីគេ?

ខ៖ អើគាត់ស្លាប់តាំងពីឆ្នាំចិតសិបបួនណោះហ្នឹងកូន។

ក៖ អ្ចឹ!

ខ៖ តាំងពីបែកប៉ុលពតហើយមកហ្នឹង!

ក៖ ចុះពីមុនគាត់ធ្វើអីគេយាយ?

ខ៖ ពីមុនគាត់ធ្វើត្នោតចិញ្ចឹមម្តាយ។

ក៖ អ្ចឹ!

ខ៖ បងប្អូនគាត់ប្រាំមួយនាក់ប្រុសសុទ្ធតែប្រុស។

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាយាយមានកូនប៉ុន្មាននាក់យាយ?

ខ៖ ខ្ញុំកូនបី។

ក៖ អ្ចឹប៉ុន្តែកូនឥឡូវប៉ុនៗណាទៅយាយ?

ខ៖ កូនគេបែកគ្រួសារអស់ហើយ!

ក៖ បីហ្នឹងបែកទាំងបីណោះយាយ?

ខ៖ ចាំ!

ក៖ ចុះកូនបងគាត់នៅណាយាយ?

ខ៖ កូនបងនៅក្នុងភូមិកូននៅស្តុកព្រៃ។

ក៖ គាត់ធ្វើអីគេទៅយាយ?

ខ៖ ធ្វើត្នោត។

ក៖ អ្ចឹចុះកូនទីពីរ?

ខ៖ កូនទីពីរហោសគេទៅអីណាប៉ោយប៉ែតគេហោសគេដើរគេដឹងធ្វើអីផងរាល់ថ្ងៃ។

ក៖ បាទយាយ!

ខ៖ កូនស្រីគេដើរប៉ុនធ្វើខ្ញុំគេដែរណាស់កូនដូចថាវា..!

ក៖ បាទយាយ!

ខ៖ ធ្វើហាងធ្វើអីចឹងទៅរត់តុរត់អីហាសណាស់។

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចុះអើកកូនពៅយាយ?

ខ៖ កូនពៅគេប្រពន្ធអង្គរបុរីហ្នឹងស្លាប់ទៅវាទៅមានប្រពន្ធនៅកំពង់ចាមហើយឥឡូវធ្វើស្រែកូន។

ក៖ បាទយាយបាទ!

ខ៖ ធ្វើស្រែប្រពន្ធណាងចក្រហាសណាស់កូន។

ក៖ បាទយាយ!

ខ៖ អាប្តីហ្នឹងធ្វើប្រែឡើងត្នោតទៅ។

ក៖ បាទចុះយាយគិតថាសំរាប់ដូចជាអើចឹងយាយកូនបងរបស់យាយគាត់អាយុប៉ុន្មានទាល់ឥឡូវយាយ?

ខ៖ ឆ្នាំឆ្លូវហាហើយម៉ែអើអាអូនហាសឆ្លូវម៉ែចម៉ាអត់ចេះរាប់ទេឆ្លូវកើតដែរយើងបែកលុនណុល។

ក៖ ចឹងហោសយាយហោស?

ខ៖ ចាំសែជាងហាសបែបសែបីសែបួនកូនខ្ញុំហាស!

ក៖ បាទយាយ!

ខ៖ ម៉ែនសែបីមានតែចូលហា។

ក៖ មានចូលហាជាងហោសយាយ?

ខ៖ បើឆ្នាំណោះអត់ដឹង។

ក៖ បាទយាយបាទចុះយាយគិតថាអើកាលយាយការការនៅជំនាន់ណាយាយ?

ខ៖ ខ្ញុំការជំនាន់អើ..!

ក៖ លុនណុល?

ខ៖ លុនណុល!

ក៖ អ៉ូពេលការហ្នឹងគេការរបៀបម៉េចយាយអោយជាថ្ពៃទឹកដោះធម្មតាណេះយាយណេះ?

ខ៖ អត់មានទឹកដោះទេកូនកាលណុងវាពុងរត់ហុកហាក់ខ្លាំងពេកយើងដែងយើងដែងចូលព្រៃចូលអីហាស!

ក៖ បាទយាយ!

ខ៖ ហើយម្ហ៉ោះហើយចាស់ៗចេះតែចាំពុងថាកូនកំព្រា។

ក៖ អ៉ូបាទយាយ!

ខ៖ ជីដូនខ្ញុំហ្នឹងហាស!

ក៖ បាទយាយ!

ខ៖ គាត់ថាកាលហ្នឹងខ្ញុំនៅកាលដែរខ្ញុំចេញពីម្តាយមីងខ្ញុំមកខ្ញុំទធ្វើខ្ញុំគេនៅភ្នំពេញប្រាំពីរឆ្នាំ។

ក៖ អ៉ូ!

ខ៖ ចាំ!

ក៖ បាទ!

ខ៖ ប្រាំពីរឆ្នាំដល់ហើយខ្ញុំមកផ្ទះវិញមកផ្ទះវិញគាត់ថាអញ់ឥឡូវអោយកូនឯងមានប្តីហើយទាន់ភ្នែកអញ់ឃើញ មាត់អញ់ស៊ីកើតត្រចៀកអញ់លឹព្រោះអញ់ទុកដាក់គេហើយហើយ!

ក៖ បាទ!

ខ៖ ទុកដាក់បងខ្ញុំហ្នឹងហាស!

ក៖ បាទយាយ!

ខ៖ ហើយដល់ហើយចឹងទៅបានខ្ញុំហ្នឹងនេះហាសខ្ញុំការការជាមួយលោកនិមន្តលោកមកឆាន់សង្គទានយើងធម្មតាកូន។

ក៖ បាទយាយ!

ខ៖ អត់មានមេក្រូមានអីទេគ្រាន់តែមានភ្លេងខ្មែរចុះដែងទាហ៉ាននៅសំរោងយោងនៅត្រាំខ្នានៅអាដែងស្អីនេះបន្ទាយក្រៅនេះហើយនៅចំបក់។

ក៖ បាទយាយ!

ខ៖ ហើយភ្នំហ្នឹងហេសភ្នំហ្នឹងហាសកូនអាយើងនៅភូមិក្រោមលួចការតើ!

ក៖ អ៉ូ!

ខ៖ គាត់ថាការអោយតែមានគូរស្រករទៅ។

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ ចុះសំរាប់យាយគិតថាយាយធ្លាប់ចេះភាសាអីផ្សេងក្រៅ?

ខ៖ កូនហាសអត់ចេះអក្សរទេអត់បានរៀនទេកូនប្រុស។

ក៖ បាទយាយ!

ខ៖ អត់រលីងហើយបើមិនជឿសាកសួរម៉ែគ្រូហោសរាល់ថ្ងៃមកនៅជាមួយម៉ែគ្រូចេះតែនៅទៅទេបណ្តុះពូជទៅមុខទេយើងវាអត់បានចេះអក្សរយើងកូនកំព្រា។

ក៖ បាទយាយ!

ខ៖

អត់មានសូម្បីតែអក្ខរ:កម្មក៏អត់បានរៀនសាណក៏អត់បានស្គាល់ហ្នឹងគេដែរទៅនៅជាមួយឱពុកមាមីងសាច់ថ្ពៃហ្នឹងគេអត់អោយយើងរៀនគេដឹយើងទៀតដឹយើងអត់អោយស៊ីបាយដេញអោយទៅមើលគោ។

ក៖ បាទយាយបាទ!

ខ៖ ចាំមើលកូនគេនោះ។

ក៖ អ៉ូចុះយាយគិតថាអើចឹងសំរាប់យាយកាលពីក្មេងយាយធ្លាប់មានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាទេយាយ?

ខ៖ អត់ដែរមានទេកូន។

ក៖ អត់ដែរមានទេយាយ?

ខ៖ ចាំ!

ក៖ ចុះយាយគិតថាអើយាយធ្លាប់ធ្វើប្រែចំការទេយាយ?

ខ៖ ខ្ញុំហេស?

ក៖ បាទ!

ខ៖ អត់ដែរផងកូន។

ក៖ ចឹងយាយប្រែចំការក៏យាយអត់ដែរធ្វើដែរ?

ខ៖ ប្រែយើងធ្វើប៉ុនចំការ។

ក៖ ជាទូទៅនៅប្រែយាយធ្វើអីទៅយាយ?

ខ៖ យើងនៅភូមិណោះហេស?

ក៖ បាទ!

ខ៖ ខ្ញុំធ្វើតែប្រែហ្នឹងហើយដល់ហើយទៅខ្ញុំលក់នុំអីកំប៉ែកកំប៉ុកអីចឹងទៅ។

ក៖ អ៉ូ!

ខ៖ ដាំដូចថាយើងក្នុងភូមិយើងហ្នឹងយើងដាំអែថាវដាំអីដាំដំឡូងដាំអីចឹងទៅគាស់ទៅស្ងោរដោតចង្កាក់លក់ចិញ្ចឹមកូនហាសណាស់កូន។

ក៖ បាទយាយ!

ខ៖ កាលកូននៅតូចៗហាសដែងពុកវាស្លាប់ទៅហាស!

ក៖ បាទយាយ!

ខ៖ ចាំកូនបីហ្នឹងហើយដល់កូនហ្នឹងវាចេះរកខ្លះទៅមានរទេះភ្លើងហ្នឹងកូនហ្នឹងអាយុដប់ពីរវាឡើងត្នោតអាបងហ្នឹងហាស!

ក៖ បាទអ៊ុំ!

ខ៖ អាយុដប់ពីរវាឡើងត្នោតដល់អស់ត្នោតចឹងទៅវាថ្ងៃណាដ្យៀនដ្យៀនទៅថ្ងៃណាអត់ដ្យៀនវាទៅរទេះភ្លើងជាមួយយាយហោសទៅជាមួយអ្នកនាំហោស!

ក៖ បាទយាយបាទ!

ខ៖ ទៅជួយលើកស្ពរលើកអីគេហាសណាស់។

ក៖ បាទយាយ!

ខ៖ បោសអីទៅអោយតែបានលុយទៅ។

ក៖ អ៉ូ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាសំរាប់ដូចជាអើតាំងពីក្មេងរហូតមកដល់ឥឡូវយាយធ្លាប់ធ្វើការងារអីគេខ្លះយាយ?

ខ៖ ខ្ញុំអត់ដែរធ្វើការងារអីទេកូនខ្ញុំធ្វើតែប្រែលក់តែនុំអីហ្នឹង!

ក៖ អ៉ូចឹងយាយដែរទៅស៊ីឈ្នួលគេទេយាយ?

ខ៖ ស៊ីឈ្នួលគេតាំងខ្ញុំនៅក្រមុំហោសតាំងជំនាន់លុនណុលហោស!

ក៖ អ៉ូយាយធ្វើអីគេទៅយាយទៅស៊ីឈ្នួលធ្វើអីគេយាយ?

ខ៖ មើលកូនមើលប្អូនជូត ច្រះផ្ទះដាំបាយដាំអីលាងចានលាងអីហ្នឹងម្ចាស់ផ្ទះខ្ញុំហ្នឹងម្ចាស់ប្រុសអើគាត់ដុកទ័រនៅពេទ្យមាលាហើយម្ចាស់ស្រីនោះអាហ្នឹងគាត់បង្រៀននៅសន្ធរមុខ

យើងនៅផ្ទះដាំបាយដាំអីជូតច្រះផ្ទះមើលកូនដ៉ែតហាសណាស់កូន។

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាអើចិញ្ចឹមសត្វយាយធ្លាប់ចិញ្ចឹមពីមុនអត់កាលយាយនៅក្មេងហាស?

ខ៖ អត់ដែរចិញ្ចឹមទេកូន។

ក៖ អ៉ូ!

ខ៖ ចិញ្ចឹមតែមាន់អីធម្មតា។

ក៖ អ៉ូ!

ខ៖ ហើយបើជ្រូកចិញ្ចឹមអត់បានទេម៉ាភូមិខ្ញុំ។

ក៖ អ៉ូម៉ែចចឹងយាយ?

ខ៖ ដាក់ទៅអោយតែបានអាបែកកំរាវគឺឈឺចាប់អូសលូងម៉ង។

ក៖ អ៉ូ!

ខ៖ ចាំគេអត់អោយចិញ្ចឹមទេភូមិខ្ញុំតាំងពីម្តាយក្មេកខ្ញុំមកខ្ញុំនៅនៅភូមិហ្នឹងនៅភូមិម៉ែក្មេកហាស!

ក៖ បាទយាយបាទ!

ខ៖ ម៉ែក្មេកខ្ញុំចិញ្ចឹមអត់បានទេកូនភូមិហ្នឹងហោស!

ក៖ អ៉ូ!

ខ៖ តាំងពីគាត់មក។

ក៖ ចុះយាយគិតថាអើដូចជាចឹងជីវិតរបស់យាយយាយគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវមានការផ្តាស់ប្តូរអីគេខ្លះយាយ?

ខ៖ អត់មានផ្តាស់ប្តូរអស៊ីអីទេធ្វើតែស្រែហ្នឹងធម្មតា។

ក៖ អ៉ូ!

ខ៖ ចាំ!

ក៖ ដូចជាសុខភាពឥឡូវហ្នឹងម៉េចដែរយាយ?

ខ៖ សុខភាពឥឡូវហោស?

ក៖ បាទយាយ!

ខ៖ សុខភាពឥឡូវនេះវាធម្មតាប៉ុនគ្រាន់វាឈឹជង្គង់នេះបន្តិចកូនហោស!

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាជីវភាពឥឡូវអីម៉េចដែរយាយ?

ខ៖ ហូបចុកបុកទំពាហ្នឹងហោស?

ក៖ បាទយាយ!

ខ៖ យើងជីវិតអ្នកបួសមានក៏ហូបទៅអត់ក៏ហីទៅជាមួយម៉ែគ្រូហ្នឹងទៅ។

ក៖ អ៉ូ!

ខ៖ ធម្មតាចឹងទៅបើសប្បុរសជនគាត់មកចឹងមានអង្ករទឹកត្រីអីម្ហូបអីបញ្ចំយអីចឹងទៅយើងទិញហូបហាសណាស់កូន។

ក៖ បាទយាយបាទ!

ខ៖ មានអំបិលយើងហូបអំបិលទៅមានប្រហុកយើងហូបប្រហុកទៅ បន្ថែប្រកាហ្នឹងយើងដាំខ្លះហូបទៅ។

ក៖ បាទត្រូវយាយ!

ខ៖ ហើយយើងទិញម្ហូបមកយើងលីងទុកទៅអាំងទុកអីចឹងទៅណាស់កូនស្តបន្ថែទៅ។

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាអើម្ហូបរបស់យាយ យាយចូលចិត្តហូបម្ហូបអីគេយាយ?

ខ៖ ខ្ញុំហោស?

ក៖ បាទយាយ!

ខ៖ ហើយហូបត្រីហូបសាច់ជ្រូកអីសាច់មាន់អីអីចឹងទៅធម្មតាទៅហើយជួនណាស្តអត់បន្ថែស្តកកូរអីចឹងទៅ

ប៉ុងតែប្រហុកទៅប៊ីចេងទៅស្តអត់ម្ហូបអីចឹងទៅតែប្រហុកប៊ីចេងអីចឹងទៅ។

ក៖ បាទយាយបាទ!

ខ៖ ល្ហុងយើងមានហ្នឹងចេកយើងមានហ្នឹង ស្ពឹកបាសស្ពឹកអីហ្នឹងចេះបេះហាសណាស់កូន។

ក៖ បាទយាយ!

ខ៖ យើងនេះហាស!

ក៖ ចុះយាយគិតថាសំរាប់ដូចជាអើយាយកាលពីក្មេងយាយធ្លាប់លេងល្បែងប្រជាប្រិយ៍អីទេ?

ខ៖ អត់ទេ។!

ក៖ លក្ខណៈបោះអង្គុញ ចោលឈូងអីហាស?

ខ៖ បោះអង្គុញ ចោឈូងធម្មតាតាវត្តយើងមួយឆ្នាំលេងម្តងអីចឹងទៅ។

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាអើដូចជាយាយចេះច្រៀងទេយាយ?

ខ៖ អត់ទេ!

ក៖ ចុះរាំយាយចេះទេ?

ខ៖ អត់ទេ!

ក៖ ចុះយាយចូលចិត្តស្តាប់ធ៍មណេះយាយណេះ?

ខ៖ ចាំ!

ក៖ ចុះណ្ឌោនយីកេអាយៃយាយចូលចិត្តមើលអត់?

ខ៖ អត់!

ក៖ ចឹងមានន័យថាយាយរាល់ថ្ងៃយាយស្តាប់តែធ៍មទេ?

ខ៖ ចាំ!

ក៖ ហ្នឹងរៀនធ៍មណេះយាយណេះ?

ខ៖ ចាំ!

ក៖ អ៉ូចុះយាយគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសារយាយចេះលេងឧបករណ៍ភ្លេងភ្លេងខ្មែរភ្លេងសៀមភ្លេងអីទេយាយ?

ខ៖ អត់!

ក៖ អត់មានទេណេះយាយ?

ខ៖ ចាំកូនចៅខ្ញុំអត់ទេកូន។

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាផ្ទះរបស់យាយមានលក្ខណៈប៉ែបណាយាយតាំងពីក្មេងរហូតមកដល់ឥឡូវហាស?

ខ៖ ខ្ញុំហេស?

ក៖ បាទយាយ!

ខ៖ កាលពីក្មេងផ្ទះហ្នឹងបើខ្ញុំដឹងមកខ្ទមទេ។

ក៖ អ៉ូបាទ!

ខ៖ ចាំម៉ែខ្ញុំហ្នឹងគាត់ក្រទេ។

ក៖ បាទយាយ!

ខ៖

ចាំក្រធ្វើខ្ទមនៅទេដល់មកខ្ញុំហ្នឹងទៀតការហើយមកនៅជាមួយម៉ែក្មេកហ្នឹងក៏ខ្ទមដែរប្តីខ្ញុំគាត់ទៅណាអត់រួចទេបងប្អូនបីអើបួននាក់បីនាក់បួននាក់នោះអើគេទៅកងទ័ពប៉ុលពតអស់ទៅបងមួយនោះមានប្រពន្ធទៅគាត់ហ្នឹងថែម្តាយថែឱពុកហ្នឹងបីឱពុកទាល់តែដាច់ខ្យល់ហ្នឹងដៃ។

ក៖ បាទយាយបាទ!

ខ៖

ចាំហើយយើងគ្រាប់ផ្លោងមកគេចាស់ៗគាត់ថាអោយដាក់ទៅគាត់ថាគាត់អត់ដាក់ទេសុខចិត្តឱពុកគាត់ស្លាប់នៅហ្នឹងដៃទាល់ឱពុកហ្នឹងដាច់ដកចំការមាន់ដាច់ខ្យល់ទៅហ្នឹងដៃហ្នឹងអាហ្នឹងខ្ញុំមកពីខ្ញុំមកពីស៊ីឈ្នួលគេវិញហើយណាស់កូន។

ក៖ បាទយាយ!

ខ៖ ចាំដល់គ្រាន់ឱពុកហ្នឹងស្លាប់ទៅបានចាស់ៗគាត់គូរផ្គងខ្ញុំជាមួយបងជីដូនមួយហ្នឹងទៅជីដូនមួយតើគ្រួសារហ្នឹង!

ក៖ អ៉ូបាទយាយបាទ!

ខ៖ ចាំគាត់ចិញ្ចឹមគាត់នៅថែឱពុកគាត់ហ្នឹង!

ក៖ អ៉ូចុះយាយគិតថាអើផ្ទះរបស់យាយកាលយាយនៅឱពុកផ្ទះម៉េចដល់ពេលឥឡូវរហូតដល់ឥឡូវផ្ទះម៉េចយាយ?

ខ៖ ឥឡូវនេះ?

ក៖ បាទយាយ!

ខ៖ ឥឡូវនេះក៏នៅខ្ទមដែរទាល់ខ្ញុំមកបួសហ្នឹងហាសហើយអាផ្ទះហ្នឹងបាក់បែកអស់ទៅកូនគេរុះដុតហើយ!

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចុះកាលផ្ទះយាយនៅហ្នឹងផ្ទះម៉េចផ្ទះឈើវឹក៏ផ្ទះថ្មយាយ?

ខ៖ ផ្ទះឈើ។

ក៖ អ៉ូ!

ខ៖ ដាងយើងហាសកូន។

ក៖ បាទយាយបាទ!

ខ៖ យើងធ្វើដាងកាប់ឈើព្រៃលើធ្វើហ្នឹង!

ក៖ បាទយាយ!

ខ៖ ចាំកាលហ្នឹងយើងបែកហើយយើងមិនដែងកាប់ឈើដឹកពីព្រៃលើទៅប្តីដឹកទៅហ្នឹងគាត់ធ្វើដាងធ្វើអីអោយគ្រាន់នៅទាំងអស់គ្នាធ្វើបានតែម៉ានេះតើហើយគាត់ស្លាប់ទៅហាស!

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាអើជំនាញអីដែរយាយចេះស្មាត់ជំនាញយាយ?

ខ៖ អត់ខ្ញុំចេះតែធ្វើស្រែហ្នឹងម៉ង។

ក៖ យាយចូលចិត្តធ្វើស្រែម៉ងយាយ?

ខ៖ ចាំ!

ក៖ បាទយាយ!

ខ៖ អត់ដែរទៅជំនឿជំនួញអីជំនាញអីផងខ្ញុំអត់ទេ។

ក៖ ចុះអ្នកមានផ្ទៃពោះអីអោះភាគច្រើនដូចជាយាយគិតថាយាយឱពុកម្តាយយាយធ្លាប់បង្រៀនអីទៅយាយអត់ដែរទេណេះយាយណេះ?

ខ៖ អត់ដែរហ្នឹង!

ក៖ អ្វំយាយអាចប្រាប់ចៅពីការលំបាករបស់យាយកាលពីក្មេងបានទេ?

ខ៖ ចុះហ្នឹងមិនការលំបាកពីក្មេងមកហ្នឹង!

ក៖ យាយពីក្មេងយាយធ្លាប់ទាន់ជំនាន់អីជំនាន់អ៊ីសារ៉ាក់ទាន់អត់?

ខ៖ អត់ទាន់ទេកូនអត់ទាន់ទេ។

ក៖ ជំនាន់ដាបឈួនយាយ?

ខ៖ អត់ទេ!

ក៖ អ្វំ!

ខ៖ ទើបទាន់ជំនាន់លោកប៉ុលពតហ្នឹង!

ក៖ ប៉ុលពតយាយច្បាស់ហោសយាយ?

ខ៖ ចាំ!

ក៖ យាយអាចប្រាប់ចៅខ្លះៗទាក់ទងពីជំនាន់ប៉ុលពតបានទេយាយថាយាយធ្លាប់ជួបការលំបាកអីដែរជួចត់អត់យាយនៅក្នុងជីវិតយាយហាស?

ខ៖ កាលជំនាន់ប៉ុលពតដែរណេះកូនណេះខ្ញុំមកពីភ្នំពេញវិញខ្ញុំការហើយហ្នឹងហាសគេអោយខ្ញុំទៅរត់ទៅនៅអើគេហៅពោងរាល។

ក៖ បាទយាយ!

ខ៖

ចាំទៅហ្នឹងទៅទាំងយប់ទាំងថ្ងៃចឹងដើរកាត់ព្រៃកាប់ព្រៃកាប់ខ្សៃទៅទៅនៅពោងរាលដល់ហើយគេអោយមកធ្វើស្រែវិញដល់មកធ្វើស្រែវិញអ្វំគេអោយថយទៀតរត់ទាំងងងឹតទាំងងងឹ

តឈឹងហ្នឹងទៅថ្នាត្រប៉ែងនេះគេហៅថ្នាត្រប៉ែងដល់តែប៉ែកទាហ៊ានហ្នឹងអស់ទៅចូលមកជំនាន់គេហ្នឹងគេធ្វើការគេអោយដ៉ែកជី

ដ៉ែកអាចម៍សែងអាចម៍ចឹងទៅហើយហ្នឹងធ្វើស្រែបាចទឹកសាបអីហ្នឹងវាដទនាណាស់កូនហើយពេលណាមានបាយហូបក៏មានទៅពេលណាអត់ហ្នឹងក៏អត់ទៅធ្វើម៉ែចជំនាន់ហ្នឹង!

ក៖ ចុះអើសំរាប់ដូចជាគេជំលាសយើងទៅណាយាយពេលណុង?

ខ៖ ចាំ!

ក៖ គេជំលាសយើងទៅណា?

ខ៖ គេជំលាសខ្ញុំទៅពោងរាល។

ក៖ ពោងរាលពោងរាលហ្នឹងនៅណាយាយ?

ខ៖ បរសែត។

ក៖ បរសែតហោស?

ខ៖ ចាំ!

ក៖ អ្វំ!

ខ៖ ហើយដល់ពេលធ្វើស្រែមកវិញមកធ្វើស្រែធ្វើស្រែហើយគេអោយទៅថ្នាទៅតឿងនេះទៀតអោយគេរួចពីគ្រាប់កាំភ្លើងហាសកូន។

ក៖ បាទយាយ!

ខ៖ អោយខុសមុខហាស!

ក៖ ចុះពេលហ្នឹងយាយអាយុប៉ុន្មានហើយយាយកាលប៉ុលពត?

ខ៖ ខ្ញុំកាលជំនាន់ប៉ុលពតហេស?

ក៖ បាទយាយ!

ខ៖ ខ្ញុំម្ភៃ។

ក៖ តែយាយមានគ្រួសារនៅយាយ?

ខ៖ នៅមានហើយដែរខ្ញុំជំលាសហ្នឹងខ្ញុំមកពីធ្វើខ្ញុំគេវិញនៅភ្នំពេញហ្នឹងនេះខ្ញុំមកវិញយាយៗម៉ែយាយខ្ញុំយាយខ្ញុំអោយមានគ្រួសារទៅ។

ក៖ អ្វំបាទយាយចឹងកាលអើចុះសំរាប់យាយគិតថាដូចជាម៉ោងការងារឹក៏ហូបចុកអីម៉ែចដែរយាយ?

ខ៖ ជំនាន់ប៉ុលពតហេស?

ក៖ បាទជំនាន់ប៉ុលពត!

ខ៖ ជំនាន់ប៉ុលពតយើងអាកាំងម៉ឹងចឹងហាសយើងយកកូនយកមកដាក់ម៉ែដោះ។

ក៖ បាទយាយ!

ខ៖ ហើយព្រលឹមឡើងហ្នឹងយើងទៅជីកប៉ូព្រកប្រព័ន្ធប៉ូព្រកប្រព័ន្ធអីគេចឹងទៅមកវិញម៉ោងដប់មួយអីចឹងទៅ

ម៉ោងដប់មួយឡើងមកវិញប៉ុនហាសកូនអើយវេទនាណាស់ដល់មកដល់ហោសពុងកាន់បង្គីប្រើគ្នាមកហាស!

ក៖ បាទយាយ!

ខ៖ មកដល់គេប្រលះបង្គីពីដៃមួយនោះគេច្រានកូនអាគេច្រានម៉ែហ្នឹងអោយចេញពីគេហាសណាស់។

ក៖ បាទយាយ!

ខ៖ អ្នកដប់ប្រាំពីរគេនាំគ្នាយកដីចោលហាសណាស់កូនខ្ញុំធ្វើការជាមួយអ្នកដប់ប្រាំពីរហាសយើងនៅតាមភូមិហាស!

ក៖ បាទយាយ!

ខ៖

ចាំវាវេទនាណាស់គ្នានោះហើយយើងមកដល់ហ្នឹងអត់ហ៊ានងៀកមើលគ្នាទេយើងរត់ហាណាស់អោយតែគេនេះគេច្រានយើងចេញហាសណាស់យើងដើរជាមួយគ្នាចុះយើងមិនដើរ

ធ្វើការមិនដង្ហែគ្នាទៅកូន។

ក៖ បាទអត់ទាន់ទេយាយ។

ខ៖ ហើយយើងហើយគេ។

ក៖ បាទយាយ!

ខ៖ គេអត់ទេគេច្រានយើងទៅមុខចេះហាសណាស់។

ក៖ បាទយាយ!

ខ៖ យើងដើរមុនីងហាសបើមិនចឹងនេះគេច្រានយើងទៅមុខគេទាញទៅហាសណាស់។

ក៖ បាទយាយ!

ខ៖ ចាំគេចូលវត្តកកោះនេះ។

ក៖ អ៊ូបាទ!

ខ៖ ចាំ!

ក៖ អ៊ូយាយគិតថាគេមានជំលាសយាយទៅណាផ្សេងអីទៀតទេយាយ?

ខ៖ អត់ទេ!

ក៖ ជំលាសតែមួយកន្លែងទេណេះយាយ?

ខ៖ ជំលាសបានពីរកន្លែង។

ក៖ អ៊ូ!

ខ៖ ចាំ!

ក៖ ជំលាសទៅណាទៀតយាយ?

ខ៖ ជំលាសបានពីរកន្លែងហ្នឹងតែទៅពោលរាលហ្នឹងហើយហ្នឹងមកថ្នាក់ត្បូងហ្នឹង!

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាអើដូចជាអើពេលណាដែរយាយចាប់ផ្តើមរកបងប្អូនឃើញយាយ?

ខ៖ បងប្អូនខ្ញុំហោស?

ក៖ បាទ!

ខ៖ បងប្អូនខ្ញុំគេទៅអើស្លីបរស៊ែតហ្នឹងដែរ។

ក៖ អ៊ូ!

ខ៖ គេដល់ប៉ែកគ្នាគេប្អូនខ្ញុំគេអោយបន្ថយទៅបរស៊ែតខ្ញុំគេយកមកនៅត្រពាំងព្រះខាងនេះហ្នឹង!

ក៖ បាទយាយបាទ!

ខ៖ ចាំអាហ្នឹងជំនាន់ប៉ុលពតហាស!

ក៖ បាទយាយ!

ខ៖ ចាំពុងពេញប៉ុលពត។

ក៖ បាទ!

ខ៖ ប៉ុនយើងថ្ងៃណាមានអង្ករហូបក៏មានទៅថ្ងៃណាអត់ក៏អត់ទៅ។

ក៖ អ៊ូបាទ!

ខ៖ ដូចតែគ្នាហ្នឹងហាសកូន។

ក៖ អាហារពេលខ្លះយើងមានបបរខ្លះយើងមានបាយចឹងហាសណេះយាយណេះអត់មានបាយណាហ៊ីយាយ?

ខ៖ បាយទាល់តែយើងច្រូតបានមានបាយហូប។

ក៖ អ៉ូ!

ខ៖ បាយហូបតែប៉ុន្មានពីរខែបីខែហ្នឹងគេបបរទៀតហើយ!

ក៖ បាទយាយ!

ខ៖ ហើយយើងដាំដំឡូងចឹងទៅ។

ក៖ បាទយាយ!

ខ៖ ហើយយើងនេះខ្ញុំនៅហ្នឹងខ្ញុំធ្វើដល់មកបែកហើយចឹងទៅស្រុកស្រួលបួលយើងរាលើថ្ងៃហ្នឹងហាស!

ក៖ បាទយាយ!

ខ៖ មុនខ្ញុំមកបួសហ្នឹងខ្ញុំធ្វើនុំបំពុង នុំពុម្ពចាំធ្វើនុំពុម្ពនុំបំពុងធ្វើឡតធ្វើអីចឹងហាសណាស់កូន។

ក៖ បាទយាយ!

ខ៖ ចេះតែដើរលក់ហាសណាស់។

ក៖ បាទ!

ខ៖ ចាំហើយហ្នឹងដាំដំឡូងយើងខ្ពះអីខ្ពះចឹងទៅស្ងោរលក់ទៅដោតចង្កាក់លក់ចឹងទៅ។

ក៖ បាទយាយចុះយាយគិតថានៅពេលដែរយើងត្រលប់ពីប៉ុលពតវិញដាច់ពីប៉ុលពតយើងពេលហ្នឹងយើងមកនៅណាយាយ?

ខ៖ ខ្ញុំកាលមកដាច់ប៉ុលពតខ្ញុំអត់មានទៅណាផងគ្រាន់តែចេញពីភូមិយើងមកនៅព្រៃៗជំលាសមកជើងហាសកូន។

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ អ៉ូយើងលាក់ខ្លួនៗតាមព្រៃហាសណាស់។

ក៖ បាទយាយ!

ខ៖ យើងមកនេះព្រោះមកចឹងមកនៅអីតាមចំការយើងជើងហាសកូន។

ក៖ បាទយាយ!

ខ៖ ធ្វើចំការជើងទៅមកនៅចំការយើង។

ក៖ ពេលហ្នឹងយើងអត់ទាន់ចាយលុយទេណេះយាយនៅចាយអង្ករនៅឡើយទេ?

ខ៖ ចាំៗ!

ក៖ អ៉ូចុះយាយគិតថាពេលណាដែរយាយចុះយាយការនៅមុនប៉ុលពតណេះយាយណេះ?

ខ៖ ខ្ញុំការពេញលុនណុលហ្នឹងម៉ង។

ក៖ អ៉ូ!

ខ៖ ចាំ!

ក៖ រួចចុះប្តីយាយធ្វើអីគេទៅពេលណុង?

ខ៖ គាត់ធ្វើត្នោតគាត់នេះដល់ពេលយើងការហើយៗរត់ម៉ងហាសកូន។

ក៖ អ៉ូ!

ខ៖ មានបានធ្វើអីគេអត់ទេ។

ក៖ បាទយាយ!

ខ៖ រត់ម៉ងហ្នឹង!

ក៖ បាទ!

ខ៖ ម៉ែយាយហ្នឹងគាត់ចិញ្ចឹមតែយាយដែរខ្ញុំនៅជាមួយហ្នឹងគាត់ចិញ្ចឹមហាសណាស់។

ក៖ បាទយាយ!

ខ៖ យើងៗជំនាន់ណុងយើងរត់ហ្នឹងមានចាយលុយណាកូនអត់មានចាយលុយទេ។

ក៖ បាទយាយ!

ខ៖ ប៉ុនស្រូវយើងមានស៊ីហាសកូន។

ក៖ បាទយាយបាទ!

ខ៖ ស្រូវយើងមានហូបអង្ករយើងមានហូបយើងរត់តែនោះទៅយើងមកចឹងទៅដូចថាកន្លះខែមកម្តងរឺមួយអាទិត្យមកម្តងចឹងទៅហាសកិនអង្ករយកហូបហាសណាស់កូន។

ក៖ បាទយាយបាទ!

ខ៖ ហើយម្ធូបហ្នឹងយើងរកខ្លួនឯងទៅ។

ក៖ បាទយាយ!

ខ៖ មានក្តាមមានខ្យងមានត្រពាំងអីចឹងទៅយើងចេះជីកស្ពហាសណុងក្នុងព្រៃហាស!

ក៖ បាទយាយបាទ!

ខ៖ ចាយទៅនៅជាមួយស្រុកគេណុងហាស!

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ រួចចុះយាយគិតថាដូចជាចឹងពេលណាដែរយាយគិតថាសប្បាយយាយ?

ខ៖ អើជីវិតខ្ញុំមួយជាតិនេះអត់មានសប្បាយហ្នឹងគេទេតាំងពីតូច។

ក៖ ចឹងហោសយាយ!

ខ៖ ចាំពិបាករហូត។

ក៖ អ៉ូ!

ខ៖ បានថាពិបាកយើងធ្វើស្រែចិញ្ចឹមកូនដែរអត់ពីប្តីទៅ។

ក៖ បាទយាយ!

ខ៖ ភ្លូរខ្លួនឯងខ្ជីគោគេ។

ក៖ បាទយាយ!

ខ៖ យើងអត់គោអត់រទេះខ្ជីគេ។

ក៖ បាទយាយ!

ខ៖ ហើយយើងអត់មានពេលកាលសប្បាយទេកូន។

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ ចុះយាយគិតថាដូចជាកាលពីក្មេងយាយធ្លាប់មានគោលបំណងថាធំឡើងយាយចង់ធ្វើអីមួយទេយាយ?

ខ៖ យើងបំណងចង់ធ្វើអីគេបើយើងអត់បានរៀនផងកូន។

ក៖ ចឹងហោសយាយ?

ខ៖ ចាំអាចិត្តនោះវាចេះតែប៉ងចង់តែធ្វើហើយធ្វើៗចង់តែមានប្រាក់ខែហូបហ្នឹងគេប៉ុន្តែយើងវាអត់ចេះអក្សរ។

ក៖ បាទយាយ!

ខ៖ ចាំ!

ក៖ អ៉ូចុះយាយគិតថាបើសិនជាចង់អោយយាយផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗយាយគិតថាយាយចង់ផ្តែផ្តាំអីទៅពួកគាត់ដែរយាយ?

ខ៖

ឥឡូវសូមជូនបុណ្យកុសលទៅដល់កូនចៅកូនខំរៀនអោយមានបញ្ញាឆ្លៀសវៃរៀនឆាប់ចំណាំឆាប់បានទៅទីណាកន្លែងណាអោយមានជោគជ័យសិរីសួរស្តីកូនខំរៀនខំសូត្រធ្វើជាក្មេងល្អកុំអោយពិបាកដូចខ្ញុំកំព្រីកំព្រាអក្សរក៏អត់ស្គាល់អោយកូនៗខំរៀនតវនបន្តសាសនាយើងបន្តទៅមុខទៀតប្រទេសជាតិយើងអោយបានរុងរឿងកុំបាក់កុំដូចខ្ញុំជំនាន់មុនខុសហើយ!

ក៖ បាទយាយបាទ!

ខ៖ ចាំ!

ក៖ ចឹងយាយមានអីផ្តែផ្តាំផ្សេងទៀតទេយាយ?

ខ៖ ផ្តាំផ្តែផ្តាំស្អីគេកូន។

ក៖ តែប៉ុណ្ណឹងទេណេះយាយណេះ?

ខ៖ ចាំ!

ក៖ អ៉ូបាទចឹងចៅអរគុណច្រើនយាយ!

ខ៖ ចាំ!

ក៖ ដែរបានអោយចៅពិភាក្សាជាមួយយាយទាក់ទងពីប្រវត្តិរបស់យាយ!

ខ៖ ចាំ!

ក៖ ចឹងហាសយាយ!

ខ៖ ចាំៗ!

ក៖ បាទ!

ខ៖ ជូនបុណ្យកុសលកូនអាយុវែងទាំងអស់គ្នា។

ក៖ បាទយាយបាទ!

ខ៖ ទៅដល់ទីកន្លែងណាអោយមានសិរីសួរស្តីកូនណា។

ក៖ បាទជូនពរម្នាក់នោះផងយាយនោះបាទអរគុណច្រើនយាយ។